**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម
# ពីថ្ងៃទី៦ ដល់ ៨ ខែធ្នូ ឆ្នាំ២០១៨

---------------

តាមការអញ្ជើញរបស់ឯកឧត្តម **ង្វៀន សួនហ៊្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ពីថ្ងៃទី៦ ដល់ ៨ ខែធ្នូ ឆ្នាំ២០១៨ ក្នុងបំណងពង្រឹងទំនាក់ទំនងមិត្តភាព និងជំរុញសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត។ ក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបសម្តែងការគួរសមជាមួយឯកឧត្តម **ង្វៀន ហ្វ៊ូជុង** អគ្គលេខាធិការបក្សកុម្មុយនីស្ត និងជាប្រធានរដ្ឋវៀតណាម និងលោកជំទាវ **ង្វៀន ធី គីមង៉ិន** ប្រធានរដ្ឋសភាជាតិវៀតណាម ហើយបានជួបទ្វេភាគីជាមួយឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** ។

ថ្នាក់ដឹកនាំវៀតណាមស្វាគមន៍យ៉ាងកក់ក្តៅទស្សនកិច្ចរបស់សម្តេចតេជោ ហ៊ុន សែន និងបានសម្តែងនូវក្តីសោមនស្សរីករាយដោយឃើញវឌ្ឍនភាពដ៏អស្ចារ្យក្នុងការអភិវឌ្ឍ និងភាពកាន់តែថ្កុំថ្កើងនៃកិត្យានុភាពរបស់ប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានសម្តែងការអបអរសាទរចំពោះសមិទ្ធិផលសេដ្ឋកិច្ច-សង្គមដ៏លេចធ្លោរបស់វៀតណាម ដែលមិនត្រឹមតែជម្រុញឲ្យវៀតណាមឈានទៅរកគោលដៅឧស្សាហូបនីយកម្ម និងទំនើបកម្មរបស់ខ្លួនប៉ុណ្ណោះទេ តែក៏រួមចំណែកផងដែរដល់កំណើនសេដ្ឋកិច្ច និងវិបុលភាពនៅក្នុងតំបន់។

ស្តីពីស្ថានភាពជាទូទៅនៃទំនាក់ទំនងទ្វេភាគី ថ្នាក់ដឹកនាំវៀតណាមបានបញ្ជាក់អំពីការត្រៀមខ្លួនទទួលស្វាគមន៍ដ៏កក់ក្តៅនូវព្រះរាជទស្សនកិច្ចរបស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រកម្ពុជា** ជាអម្ចាស់ជីវិតលើត្បូង នៅប្រទេសវៀតណាម ក្នុងពេលមុនដំណាច់ឆ្នាំនេះ ដែលនឹងរួមចំណែកលើកកម្ពស់ចំណងមិត្តភាពជាប្រពៃណីរវាងកម្ពុជា និងវៀតណាម បន្ថែមលើទស្សនកិច្ចជាន់ខ្ពស់ឯទៀតក្នុងពេលថ្មីៗកន្លងទៅនេះ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំវៀតណាមបានរំលឹកអំពីមិត្តភាព និងសាមគ្គីភាព

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855) 23 214 441, 216 122
ទូរសារ: (855) 23 216 144, 216 141
វិបសាយ: ...gov.kh

ដែលប្រជាជាតិទាំងពីរបានបន្តថែបំប៉នជាយូរមកហើយ និងបានគូសបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តពង្រឹង និងពូនជ្រុំបន្ថែមនូវទំនាក់ទំនាក់ជាភាតរៈ ភាពជាអ្នកជិតខាងល្អ ទំនុកចិត្តទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាដើម្បីបំរើផលប្រយោជន៍ប្រជាជនទាំងពីរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំវៀតណាមក៏បានឯកភាពគ្នារៀបចំរំលឹកខួបអនុស្សាវរីយ៍លើកទី៤០នៃការតស៊ូរួមគ្នាដើម្បីរំលំរបបប្រល័យពូជសាសន៍ប៉ុលពត។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិភាក្សាគ្នាជាមួយឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** ក្នុងបរិយាកាសស្និទស្នាល និងត្រង់ៗ លើបញ្ហាជាច្រើនពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ក៏ដូចជាពហុភាគី។ ថ្នាក់ដឹកនាំទាំងពីរបានសម្តែងការពេញចិត្តចំពោះកំណើនទំហំពាណិជ្ជកម្មទ្វេភាគី និងឯកភាពបន្តប្រឹងប្រែងសម្រេចឲ្យបាន និងឲ្យលើសពីគោលដៅទំហំពាណិជ្ជកម្ម ៥ពាន់លានដុល្លាអាមេរិក នៅឆ្នាំ២០២០។ ក្នុងន័យនេះ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពមតិគ្នាថាប្រទេសទាំងពីរគួរខិតខំអនុវត្តឲ្យបានពេញលេញនូវកិច្ចព្រមព្រៀងដែលមានស្រាប់ និងចុះកិច្ចព្រមព្រៀងចាំបាច់បន្ថែមទៀតដើម្បីធ្វើឲ្យកាន់តែប្រសើរនូវការតភ្ជាប់គ្នា សម្របសម្រួលការដឹកជញ្ជូន និងច្រកចេញចូលឆ្លងដែន ជម្រុញការផ្លាស់ប្តូរពាណិជ្ជកម្ម ធុរកិច្ច វិនិយោគ ទេសចរណ៍ និងពង្រីកកិច្ចសហការផ្គត់ផ្គង់ថាមពល។

ស្តីពីការងារសន្តិសុខ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានប្តេជ្ញាបង្កើនកិច្ចសហប្រតិបត្តិការ និងការចែករំលែកពត៌មានគ្នាឲ្យបានទាន់ពេលវេលា ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងការកាប់ឈើខុសច្បាប់ ក៏ដូចជាកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិ។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានផ្លាស់ប្តូរយោបល់ផងដែរអំពីកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ និងវប្បធម៌។ ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានឯកភាពសំណើរៀបចំឲ្យមានកិច្ចព្រមព្រៀងស្តីពីការទប់ស្កាត់ការលួច និងការជួញដូរសម្បត្តិវប្បធម៌នៃប្រទេសទាំងពីរ។

**សម្តេចតេជោ ហ៊ុន សែន** និងឯកឧត្តម **ង្វៀន សួនហ៊្វុក** បានពិភាក្សាយ៉ាងទូលំទូលាយអំពីការដោះស្រាយបញ្ហាព្រំដែន។ ថ្នាក់ដឹកនាំទាំងពីរស្វាគមន៍សមិទ្ធិផលនៃការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនកន្លងមក និងបានឯកភាពគ្នាជំរុញឲ្យគណកម្មការចំរុះខ័ណ្ឌសីមាព្រំដែនទាំងសងខាងពន្លឿនការដោះស្រាយបញ្ចប់បញ្ហាព្រំដែនគោកដែលនៅសេសសល់ ចំនួន១៦ភាគរយផ្អែកលើស្មារតីនៃមិត្តភាព និងភាពជាអ្នកជិតខាងល្អ សំដៅកសាងខ្សែបន្ទាត់ព្រំដែនរួមប្រកបដោយមិត្តភាព សន្តិភាព ស្ថិរភាព និងសហប្រតិបត្តិការរឹងមាំយូរអង្វែងសម្រាប់ប្រជាជនជំនាន់ក្រោយៗ។

ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគី **សម្តេចតេជោ ហ៊ុន សែន** និងឯកឧត្តម **ង្វៀន សួនហ៊្វុក** ក៏បានតាំងចិត្តធ្វើការជិតស្និទជាមួយគ្នាដើម្បីរួមចំណែកកសាងអាស៊ានដែលមានសាមគ្គីភាពរឹងមាំ និងខំទាញផលប្រយោជន៍ឲ្យបានជាអតិប្បរិមាពីសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអនុតំបន់ ជាអាទិ៍ ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងមហាអនុតំបន់មេគង្គ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព២០៣០។ សម្តេចតេជោ និងនាយករដ្ឋមន្ត្រីវៀតណាមក៏បានសន្យាគាំទ្រគ្នាទៅវិញទៅមកឲ្យសម្រេចបានជោគជ័យនៅពេលកម្ពុជាធ្វើម្ចាស់រៀបចំកិច្ចប្រជុំកំពូលអាស៊ីអ៊ឺរ៉ុប ហើយវៀតណាមធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២០។

ក្រោយជំនួបទ្វេភាគី **សម្តេចតេជោ ហ៊ុន សែន** និងឯកឧត្តម **ង្វៀន សួនហ៊្វុក** បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើឯកសារចំនួន៥ គឺ៖ (១) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីយុទ្ធសាស្រ្តសហប្រតិបត្តិការលើវិស័យដឹកជញ្ជូនសម្រាប់ឆ្នាំ២០១៨-២០២៥ និងទស្សនៈវិស័យឆ្នាំ២០៣០ (២) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបញ្ចប់កិច្ចចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែន (៣) ផែនការសហប្រតិបត្តិការវិស័យអប់រំឆ្នាំ២០១៩ (៤)កំណត់ហេតុកិច្ចប្រជុំរវាងគណៈកម្មការចម្រុះខ័ណ្ឌសីមាព្រំដែននៃប្រទេសទាំងពីរ (៥)អនុស្សរណៈយោគយល់គ្នាស្តីពីគម្រោងសាងសង់មជ្ឈមណ្ឌលផ្តល់សេវាកម្មព្យាបាលដោយស្ម័គ្រចិត្ត នៅកំរិតសហគមន៍សម្រាប់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ។

នាយករដ្ឋមន្ត្រីទាំងពីរបានធ្វើជាអធិបតីក្នុងវេទិកាធុរកិច្ច និង វិនិយោគរវាងវៀតណាម-កម្ពុជា ដែលមានតំណាងផ្នែកធុរកិច្ចពីកម្ពុជា និងវៀតណាមប្រមាណ៤០០នាក់ចូលរួម ដោយបានសន្យាផ្តល់ជំនួយ និងសម្របសម្រួលដល់ការផ្លាស់ប្តូរធុរកិច្ច និងវិនិយោគរវាងប្រទេសទាំងពីរ។

ក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានអញ្ជើញដាក់កម្រងផ្កានៅវិមានអនុស្សាវរីយ៍បុព្វបុរស និងយុទ្ធជនពលី នៅវិមានតម្កល់សពលោកប្រធានហូជីមិញ និងបានអនុញ្ញាតឲ្យគណៈប្រតិភូសមាគមមិត្តភាពវៀតណាម-កម្ពុជា ចូលជួបសម្តែងការគួរសមផងដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញឯកឧត្តមនាយករដ្ឋមន្ត្រី**ង្វៀន សួនហ៊្វុក** មកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា តាមពេលវេលាសមស្រប។ ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានទទួលយកដោយរីករាយនូវការអញ្ជើញនេះ។៚

ថ្ងៃសៅរ៍ ១កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨